Alameda County Social Services Agency

ALAMEDA COUNTY COMMUNITY FOOD BANK

CalFresh FOOD

# អត្ថប្រយោជន៍ EXTRA CalFresh របស់អ្នកបានបញ្ចប់ហើយ។ មិនមែនជាអត្ថប្រយោជន៍ CalFresh ទូទៅរបស់អ្នកទេ។

ចាប់ពីខែមេសា ឆ្នាំ **2023** អ្នកនឹងមិនទទួលបានប្រាក់ជំនួយសម្រាប់គ្រាអាសន្ន **(Emergency Allotments)** ដែលជាការដាក់បញ្ចូលប្រាក់អត្ថប្រយោជន៍ **CalFresh** ទីពីរទៅក្នុងកាត **EBT** របស់អ្នកប្រចាំខែនីមួយៗទៀតទេ។ ប្រាក់ជំនួយសម្រាប់គ្រាអាសន្ន **CalFresh** បានបញ្ចប់នៅថ្ងៃទី **28** ខែកុម្ភៈ ឆ្នាំ **2023** ហើយការផ្តល់លើកចុងក្រោយបានធ្វើឡើងនៅថ្ងៃទី **26** ខែមីនា ឆ្នាំ **2023**។

## តើ CalFresh Emergency Allotments ជាអ្វី?

ប្រាក់ជំនួយសម្រាប់គ្រាអាសន្ននេះគឺជាប្រាក់ “បន្ថែម” ដែលត្រូវបានដាក់បញ្ចូលទៅក្នុងកាត EBT របស់អ្នកនៅចុងខែនីមួយៗ។ ចាប់ពីខែមេសា ឆ្នាំ 2023 អ្នកដែលទទួលបានអត្ថប្រយោជន៍ CalFresh នឹងទទួលបានចំនួនទឹកប្រាក់អត្ថប្រយោជន៍ទូទៅដែលគ្រួសារមានសិទ្ធិទទួលបានតែប៉ុណ្ណោះ។ ចំនួនទឹកប្រាក់នោះនឹងដាក់បញ្ចូលមួយដងប្រចាំខែទៅក្នុងកាត EBT របស់អ្នកក្នុងរយៈពេល 10 ថ្ងៃដំបូងនៃខែនីមួយៗដូចសព្វដង។

## តើខ្ញុំគួរធ្វើបែបណា?

ដើម្បីឱ្យប្រាកដថាអ្នកកំពុងទទួលបានអត្ថប្រយោជន៍ទាំងអស់ដែលអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចទទួលបាន សូមរាយការណ៍ពីការផ្លាស់ប្តូរទាំងឡាយនៅក្នុងស្ថានភាពរបស់អ្នកទៅកាន់ទីភ្នាក់ងារសេវាសង្គម Alameda County ដោយរួមបញ្ចូល៖

- អាសយដ្ឋានរបស់អ្នក
- ការថយចុះនៃប្រាក់ចំណូលក្នុងគ្រួសាររបស់អ្នក
- ការចំណាយចំពោះលំនៅដ្ឋាន
- ការចំណាយលើបុគ្គលដែលពឹងផ្អែកលើអ្នក ឬការថែទាំកុមារ
- ថ្លៃចំណាយលើការព្យាបាលវេជ្ជសាស្ត្រ (លុះត្រាតែអ្នកមានអាយុចាប់ពី 60 ឆ្នាំឡើង ឬមានពិការភាពប៉ុណ្ណោះ)

អ្នកអាចដាក់បញ្ជូនភស្តុតាងនៃការផ្ទៀងផ្ទាត់ការផ្លាស់ប្តូរណាមួយតាមអ៊ីនធឺណិតបានតាមរយៈ **mybenefitscalwin.org, getcalfresh.org/docs,** ឬ **virtualkiosk.acgov.org**

## តើមានធនធានផ្សេងទៀតទេ?

យើងអាចភ្ជាប់អ្នកទៅនឹងធនធាននៅក្នុងសហគមន៍ដើម្បីជួយចិញ្ចឹមគ្រួសាររបស់អ្នក។

### → FoodNow.net

ឧបករណ៍ Food Locator ដើម្បីស្វែងរកអាហារឥតគិតថ្លៃដែលនៅជិតអ្នក រួមទាំងអាហារក្តៅៗ និងគ្រឿងទេស។ ចូលទៅកាន់ **FoodNow.net** ឥឡូវនេះ។

### → Women, Infants & Children (WIC)

កម្មវិធី WIC អាចផ្តល់ប្រភេទអាហារដូចជាទឹកដោះគោ ម្សៅទឹកដោះគោ និងស៊ុតសម្រាប់ស្ត្រីមានផ្ទៃពោះ កុមារអាយុក្រោម 5 ឆ្នាំ និងទារក។ សូមដាក់ពាក្យឥឡូវនេះតាមរយៈ **acphd.org/wic**

### → Market Match

ធ្វើឱ្យប្រាក់ដុល្លារ CalFresh របស់អ្នកកើនឡើងទ្វេដងនៅទីផ្សារកសិករតាមរយៈកម្មវិធី Market Match។ ស្វែងយល់បន្ថែមតាមរយៈ **MarketMatch.org**

ប្រសិនបើអ្នកមានសំណួរអំពីការផ្លាស់ប្តូរចំពោះអត្ថប្រយោជន៍នេះ សូមទូរសព្ទទៅលេខ៖

**1-888-445-1955**

**សម្រាប់ព័ត៌មានអំពីវិធីរាយការណ៍ពីការផ្លាស់ប្តូរ សូមស្កេននៅទីនេះ។**

កេនខ្ញុំ